# អ្នកនាំសារ
# The Messenger

29



# អបអរសាទរបុណ្យព្រះយេស៊ូប្រសូត!

ខែវិច្ឆិកា-ធ្នូ ឆ្នាំ២០០៥- ព័ត៌មានសម្រាប់ប្រើប្រាស់តែនៅក្នុងព្រះសហគមន៍កាតូលិកប៉ុណ្ណោះ

រូបក្រប: កុមារី. ប៉ាង កាណារី

# អភិបូជាថ្ងៃអាទិត្យ

## សំនួរក្មេងៗ



តើហេតុអ្វីបានជានាងម៉ារីដាក់ព្រះឱរសយេស៊ូនៅក្នុងស្នូកដាក់ចំណីសត្វ ?

យ៉ូសែប និងនាងម៉ារីបានធ្វើដំណើរទៅកាន់ភូមិបេថ្លេហិម នៃស្រុកយូដា ដែលជាភូមិកំណើតរបស់លោកយ៉ូសែប ដើម្បីចុះឈ្មោះនៅក្នុងបញ្ជីជំរឿនតាមព្រះរាជក្រឹត្យដាក់ចុះរបស់ព្រះអធិរាជសេសារ អូហ្គូស។ នៅពេលទៅដល់ នាងម៉ារីក៏ឈឺផ្ទៃសម្រាលបុត្រ។ ប៉ុន្តែមិនមានកន្លែងសម្រាប់ស្នាក់នៅណាមួយសោះឡើយ។ ទោះជាយ៉ាងណាក៏ដោយ អ្នកទាំងពីរក៏ត្រូវស្វែងរកកន្លែងស្ងប់ស្ងាត់មួយដើម្បីឱ្យនាងម៉ារីអាចសម្រាលបុត្របានដែរ។ ទីបំផុតអ្នកទាំងពីរក៏ចូលទៅក្នុងក្រោលសត្វមួយ។ យ៉ាងហោចណាស់ វាក៏គ្រាន់បើជាងស្ថិតនៅខាងក្រៅដែរ។ ដង្ហើមរបស់សត្វបានកម្តៅខ្យល់អាកាស។ ចំណែកឯចំបើងវិញ ក៏បានក្លាយជាពូកសម្រាប់គេងយ៉ាងទន់ល្មើយ។ គួរឱ្យស្ងប់សុខអ្វីម្ល៉េះទេ! ជាចុងក្រោយ ទារកបានប្រសូតមកដោយស្ងប់ស្ងាត់។ នាងម៉ារីបានដាក់ព្រះឱរសយេស៊ូឱ្យផ្ទំនៅក្នុងស្នូកមួយដែលគេប្រើសម្រាប់ដាក់ចំណីឱ្យសត្វស៊ី។ ទោះបី នេះគឺជាកន្លែងផ្ទំដ៏គួរឱ្យអស់សំណើចសម្រាប់ព្រះមហាក្សត្រមួយអង្គ ប៉ុន្តែ ព្រះឱរសយេស៊ូមានសារៈសំខាន់ជាងអស់អ្នកដែលមានអំណាចនៅលើផែនដីនេះទៅទៀត។ បើគិតតាមរបៀបម្យ៉ាងទៀត ព្រឹត្តិការណ៍នេះអាចឱ្យយើងយល់ដឹងបានថា ព្រះយេស៊ូគ្រីស្តព្រមទាំងរូបកាយទ្រង់គឺជាចំណីអាហារសម្រាប់ឱ្យយើងទាំងអស់គ្នាបានបរិភោគដើម្បីរស់រានមានជីវិតនៅលើពិភពផែនដីយើងនេះ។

P.R

## ថ្ងៃអាទិត្យ ទី៤ ខែធ្នូ ឆ្នាំ២០០៥ អាទិត្យទី២

ក្នុងរដូវរអបអរសាទរព្រះគ្រីស្តយាងមក

# ព្រះយេស៊ូធ្វើពិធីជ្រមុជទឹកក្នុងព្រះវិញ្ញាណ

(មក១,១-៨)

សព្វថ្ងៃ យើងប្រកាសដំណឹងល្អអំពី "ការចាប់ផ្តើមដំបូងនៃដំណឹងល្អ"។ ដំណឹងល្អ គឺជាបុគ្គលម្នាក់ គឺលោកយេស៊ូជាព្រះគ្រីស្ត និងជាព្រះបុត្រារបស់ព្រះជាម្ចាស់។

យើងទទួលដំណឹងល្អនេះដោយសារបុរសម្នាក់ ដែលរស់នៅវាលរហោឋាន មានឈ្មោះថា "យ៉ូហាន" ឬយើងហៅថា "យ៉ូហានបាទីស្ត" ដែលមានន័យថា "អ្នកជ្រមុជពួកសាវ៉កទៅក្នុងទឹក"។ ពេលលោកយ៉ូហានប្រកាស ឱ្យអ្នកស្រុកប្រែចិត្តគំនិត គឺលោកមានបំណងតែមួយដើម្បីរៀបចំផ្លូវថ្វាយព្រះគ្រីស្ត។ ពេលលោកប្រកាសថា "មានម្នាក់នឹងមកក្រោយខ្ញុំ"។ លោកជ្រើសរើសអត្ថបទមួយឃ្លារបស់ ព្យាការីអេសាយ មកគូសបញ្ជាក់ថា: "ខ្ញុំគ្រាន់តែជាសម្លេងបុរសម្នាក់ ដែលមករៀបចំផ្លូវថ្វាយព្រះគ្រីស្ត ដែលនឹងយាងមក"។ លោកយ៉ូហាន បញ្ជាក់យ៉ាងច្បាស់ទៀតថា: "ពិធីជ្រមុជទឹក ដែលខ្ញុំធ្វើដល់អ្នករាល់គ្នា និងពិធីជ្រមុជ ដែលលោកមកក្រោយខ្ញុំធ្វើ គឺខុសគ្នាឆ្ងាយណាស់! ខ្ញុំជ្រមុជអ្នករាល់គ្នាក្នុងទឹកជាកាយវិការរបស់មនុស្ស ដែលបង្ហាញពីបំណងចង់ផ្លាស់ប្តូរការរស់នៅប៉ុណ្ណោះ ប៉ុន្តែលោកដែលមកក្រោយខ្ញុំនឹងជ្រមុជអ្នករាល់គ្នាក្នុងព្រះវិញ្ញាណដ៏វិសុទ្ធវិញ។ កាយវិការនេះមិនមែនជាកាយវិការរបស់មនុស្សទេ ប៉ុន្តែជាកាយវិការព្រះជាម្ចាស់"។

ព្រះយេស៊ូយាងមកក្នុងលោកនេះ ព្រះអង្គជ្រមុជយើងក្នុងព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ ដែលជាព្រះអំណោយទានហួសអំពីការទន្ទឹងរង់ចាំរបស់យើងទៅទៀត។ យើងត្រូវតែទទួលព្រះអំណោយទាននេះ ព្រមទាំងអរព្រះគុណដល់ព្រះអង្គផងដែរ។

## ថ្ងៃអាទិត្យ ទី១១ ខែធ្នូ ឆ្នាំ២០០៥ អាទិត្យទី៣

# ក្នុងចំណោមយើង មានម្នាក់ យើងពុំស្គាល់

(យហ១,៦-៨ ; ១៩-២៨)

ពេលលោកយ៉ូហានបាទីស្តធ្វើដំណើរទៅដល់ច្រាំងទន្លេយ័រដាន់ ពេលនោះមានពួកអ្នកកាន់អំណាចខាងសាសនាមកពីក្រុងយេរូសាឡឹមសុំជួបលោក ហើយសួរថា: "តើលោកឬ ជាព្រះមេស្ស៊ី ដែលពួកយើងរង់ចាំនោះ?"។ គេសួរលោករហូតដល់ទៅបីដងថា លោកជានរណា? "លោកជាព្រះគ្រីស្ត ឬជាលោកអេលី ឬជាព្យាការីដ៏ប្រសើរណាមួយ?"។ លោកយ៉ូហានឆ្លើយថា: "មិនមែនខ្ញុំទេ ខ្ញុំគ្រាន់តែជាសម្លេងរបស់បុរសម្នាក់ ដែលស្រែកនៅវាលរហោឋាន បង្ហាញអំពីព្រះគ្រីស្តប៉ុណ្ណោះ ព្រះគ្រីស្តយាងមក នៅជិតអ្នករាល់គ្នាហើយ តែអ្នករាល់គ្នាមិនស្គាល់ព្រះអង្គទេ ព្រះអង្គគង់នៅកណ្តាលចំណោមអ្នករាល់គ្នា"។ ពួកបណ្ឌិតឫដូច្នេះ ក៏នាំគ្នាសំដៅមករករូបលោក ប៉ុន្តែលោកនាំបណ្តាជនឆ្ពោះទៅព្រះគ្រីស្តវិញ។ លោកយ៉ូហានប្រៀបដូចចង្កៀង ប៉ុន្តែលោកមិនមែនជាពន្លឺទេ។

តាំងពីដើមរៀងមក គ្រីស្តបរិស័ទតែងប្រកាសថា ព្រះគ្រីស្តគង់នៅកណ្តាលចំណោមពួកគេហើយ។ យើងជាគ្រីស្តបរិស័ទ យកចិត្តទុកដាក់ស្វែងរកទីសម្គាល់ ដែលបញ្ជាក់ថាព្រះគ្រីស្តគង់ក្នុងលោកនេះ។ ឧទាហរណ៍ ពេលណាមានមនុស្សម្នាក់ប្រព្រឹត្តអំពើល្អសម្រាប់អ្នកដទៃ ដោយគ្មានរកប្រយោជន៍ផ្ទាល់ខ្លួននោះ មានន័យថា ព្រះអង្គគង់នៅក្នុងលោកនេះហើយ។

អ្នកក្រីក្រជាអគ្គសញ្ញានៃវត្តមានព្រះគ្រីស្ត។ តើយើងធ្លាប់ទទួលស្គាល់ព្រះអង្គឬយ៉ាងណា?



## ថ្ងៃអាទិត្យ ទី១៨ ខែធ្នូ ឆ្នាំ២០០៥ អាទិត្យទី៤

# គេថ្វាយព្រះនាមដល់បុត្រដ៏វិសុទ្ធថា ព្រះបុត្រារបស់ព្រះជាម្ចាស់ (លក១,២៦-៣៨)

លោកលូកាមានបំណងពន្យល់ថា ព្រះឱរសយេស៊ូដែលកើតពីនាងម៉ារី ជាព្រះគ្រីស្ត និងជាព្រះបុត្រាព្រះជាម្ចាស់តាំងពីមុនប្រសូតមកម្ល៉េះ។

លោកលូកានិពន្ធកំណើតព្រះយេស៊ូ តាមរបៀបប្រជាប្រិយមួយដ៏អស្ចារ្យ គឺជារបៀបនិទានក្នុងព្រះគម្ពីរ ដើម្បីពន្យល់ជំនឿរបស់គ្រីស្តបរិស័ទលើព្រះយេស៊ូ។

ថ្ងៃមួយនោះ មានទេវទូតមួយអង្គមកជូនដំណឹងនាងម៉ារីថា នាងនឹងទៅជាមាតារបស់ទារកម្នាក់។ ក្នុងព្រះគម្ពីរ កាលណាមានចែងអំពីទេវទូតមកជូនដំណឹង នោះជាព្រះបន្ទូលមកពីព្រះជាម្ចាស់។ ក្នុងអត្ថបទនេះ ព្រះជាម្ចាស់បង្ហាញការអស្ចារ្យបីសំខាន់ៗ ដែលមនុស្សយើងមិនអាចយល់ដោយខ្លួនឯងបាន។ ទេវទូត ដែលជូនដំណឹងដល់នាងម៉ារីអំពីការអាថ៌កំបាំងរបស់ព្រះយេស៊ូនោះ សព្វថ្ងៃ ក៏ជូនដំណឹងនេះដល់យើងជាគ្រីស្តបរិស័ទ ដែលអានអត្ថបទនេះដែរ។ សូមចាប់អារម្មណ៍អំពីព្រះនាមទាំងប៉ុន្មានដែលទេវទូតបានថ្វាយព្រះយេស៊ូ មានដូចជា "ព្រះបុត្រារបស់ព្រះដ៏ខ្ពង់ខ្ពស់បំផុត" "បុត្រដ៏វិសុទ្ធ" "ព្រះបុត្រានៃព្រះជាម្ចាស់"។ ព្រះយេស៊ូគឺជា ស្តេចដាវីឌថ្មី ដែលគ្រងរាជ្យគ្មានទីបញ្ចប់។

នៅចំពោះមុខទេវទូត នាងម៉ារីឆ្លើយដោយសុភាពរាបសាថា: "ខ្ញុំជាអ្នកបម្រើរបស់ព្រះជាអម្ចាស់"។

## ថ្ងៃអាទិត្យ ទី២៥ ខែធ្នូ ឆ្នាំ២០០៥



# "កុំភ័យខ្លាចអ្វីឡើយ ខ្ញុំជូនដំណឹងល្អមួយ" (លក២,១-១៧)

ជារៀងរាល់ឆ្នាំយើងអានឡើងវិញនូវអត្ថបទស្តីអំពីព្រះយេស៊ូប្រសូត។ ក្នុងអត្ថបទ លោកលូកាបានរៀបរាប់ប្រាប់យើង ជាដំបូង អំពីព្រះចៅអធិរាជរ៉ូម៉ាំងចេញបញ្ជាមួយឱ្យធ្វើជំរឿនប្រជាជន។ ដោយសារបញ្ជានេះ ប្រជាជនក្នុងចក្រភពបានធ្វើដំណើរយ៉ាងអ៊ូអែទៅចុះឈ្មោះតាមភូមិស្រុក រៀងៗខ្លួន។ ពេលនោះ លោកយ៉ូសែប និងនាងម៉ារីក៏ចាកចេញ ពីភូមិណាសារ៉ែតទៅបេថ្លេហិមនៃស្រុកយូដា ដែលជាភូមិកំណើតរបស់ខ្លួនផងដែរ។ ពេលទៅដល់នាងម៉ារីក៏ប្រសូតបានបុត្រដំបូងម្នាក់។

នៅឯស្ថានបរមសុខវិញ ទេវទូតទាំងឡាយហោះហើរអ៊ូអែ មកផែនដី ប្រកាសប្រាប់ពួកគង្វាលថា "កុំខ្លាចអ្វីឡើយ ខ្ញុំជូនដំណឹងល្អមួយដល់អ្នករាល់គ្នា"។ "កុំខ្លាចអ្វីឡើយ" គឺកុំឱ្យភ័យខ្លាចអ្វីអំពីទារកដ៏តូចដែលទើបនឹងប្រសូតនេះ។ "ដំណឹងល្អ" គឺថា ព្រះជាម្ចាស់កើតជាមនុស្សដើម្បីឱ្យយើងឈប់ភ័យខ្លាច។ ព្រះជាម្ចាស់កើតមកជាបុត្រមនុស្សដើម្បីឱ្យមនុស្សទៅជាព្រះជាម្ចាស់។

ថ្ងៃនេះ ព្រះសង្គ្រោះរបស់អ្នករាល់គ្នាមួយអង្គប្រសូតមកក្នុងភូមិកំណើតរបស់ព្រះបាទដាវីឌ! គឺជាព្រះយេស៊ូ ជាព្រះសង្គ្រោះ។ ព្រះអង្គជាព្រះគ្រីស្ត គឺជាស្តេច និងជាព្រះអម្ចាស់ !

មានសុភមង្គលហើយ ! ព្រោះមានទេវទូតមកប្រកាស ប្រាប់អំពីអាថ៌កំបាំងរបស់ទារកនេះដល់យើង ! ភ្នែកយើងរាល់គ្នាមើលមិនឃើញការណ៍អាថ៌កំបាំងអំពីទារកដ៏តូចដែលទើបនឹងប្រសូតពីគ្រួសារក្រីក្រនេះទេ ក៏ដូចជាទារកពីក្នុងគ្រួសារផ្សេងៗទៀតដែរ។

តែព្រះជាម្ចាស់ទតឃើញថា ទារកដ៏តូចនេះជាព្រះបុត្រាជាទីស្រឡាញ់របស់ព្រះអង្គទៅវិញ។

សូមថ្លែងអំណរគុណដល់ក្រុមការងារមណ្ឌលវប្បធម៌កាតូលិកដែលជួយសហការយ៉ាងកក់ក្តៅ !



## បុណ្យព្រះយេស៊ូប្រសូតសម្រាប់លោកអភិបាល អេមីល ដេតម្បូ នៅថ្ងៃនេះ!



នៅប្រទេសកម្ពុជា ប្រជាជនតែងនិយាយថាបុណ្យព្រះយេស៊ូប្រសូតជាបុណ្យដ៏រុងរឿង និងឱឡារិករបស់គ្រីស្តបរិស័ទ គឺដូចជា បុណ្យពិសាខបូជាជាបុណ្យដ៏ប្រសើរឧត្តុងឧត្តមរបស់បងប្អូនពុទ្ធបរិស័ទដែរ។ រូបភាពដែលគេស្គាល់ច្បាស់ជាងគេ គឺរូបក្រោលសត្វពាហនៈ និងមានព្រះកុមារយេស៊ូដេកនៅក្នុងស្នូកចំណីសត្វ ហើយមាននាងម៉ារីជាម្តាយនិងលោកយ៉ូសែប ជាឪពុកនៅក្បែរព្រះកុមារយេស៊ូ។ មានអ្នកឃ្វាលចៀម និងប្រជាជនក្រីក្រនាសម័យនោះនៅជិតឪពុកម្តាយព្រះយេស៊ូ ពួកគេនាំយកតង្វាយមកថ្វាយព្រះកុមារ ដូចជាផ្លែឈើដែលគេបានដាំដុះ គឺជាប្រជាជនក្រីក្រ ដែលយកអ្វីដែលគេមានមកថ្វាយព្រះកុមារ។

ទាំងអស់គ្នាគយគន់ទស្សនីយភាពនេះយ៉ាងយកចិត្តទុកដាក់ និងស្ញើចសរសើរ។ នៅក្នុងការស្ញើចសរសើរនោះប្រហែលជាគេសម្តែងចិត្តអាណិតអាសូរចំពោះទារក ដែលទើបនឹងប្រសូតមកដេកនៅក្នុងស្នូកចំណីសត្វ ហើយឪពុកម្តាយ ដែលនៅជិតទារកមានសម្លៀកបំពាក់តែមួយសម្រាប់គត់។ សម្រាប់គ្រីស្តបរិស័ទវិញ ទស្សនីយភាពនេះគឺជាព្រឹត្តិការណ៍ដ៏អស្ចារ្យនៃជំនឿរបស់គេ ជាព្រឹត្តិ-ការណ៍ នៃសេចក្តីស្រឡាញ់ដ៏លើសលប់របស់ព្រះជាម្ចាស់។ "ព្រះជាម្ចាស់យកកំណើតជាមនុស្សដើម្បីឱ្យមនុស្សទៅជាព្រះម្ចាស់" នេះជាឃ្លារបស់លោកអភិបាលម្នាក់សរសេរតាំងពីច្រើនសតវត្សរ៍។ បុណ្យព្រះយេស៊ូប្រសូតមិនមែនជាបុណ្យកន្លងផុតទៅនោះទេ ពីព្រោះព្រះយេស៊ូប្រសូត នៅថ្ងៃនេះនិងកន្លែងនេះ។ ចំពោះអស់អ្នកដែលទទួលស្គាល់ថាព្រះអម្ចាស់គង់នេះក្នុងចំណោមបងប្អូនដែលកំពុងរស់នៅជុំវិញគេនោះ គេក៏ទទួលស្គាល់ថាបុណ្យព្រះយេស៊ូប្រសូតបានប្រារព្ធធ្វើជារៀងរាល់ថ្ងៃដែរ ហើយគ្រប់ពេលវេលា ព្រះភក្ត្រព្រះយេស៊ូ ជួនស្រស់ថ្លា ជួនឈឺចាប់ខ្លោចផ្សា។ ព្រះអង្គបង្រួបបង្រួមមនុស្សលោក ជាបងប្អូនគ្នានឹងគ្នាពិសេសអស់អ្នកក្រីក្រកំសត់ទុគ៌ត និងអស់អ្នកដែលត្រូវគេបោះបង់ចោលមិនរាប់រក។

ជូនពរអំណររីករាយបុណ្យព្រះយេស៊ូប្រសូត។

# ត្រឡប់ពីតៃហ្សេ



Photo: DR

ក្រុមគ្រីស្តបរិស័ទបានវិលត្រឡប់មកដល់ប្រទេសកម្ពុជាវិញ បន្ទាប់ពីបានធ្វើដំណើរទៅកាន់ប្រទេសបារាំងដើម្បីធ្វើតៃហ្សេ។ កញ្ញាស្រីម៉ិច បានបង្ហាញនូវអារម្មណ៍នាងថា: "ខ្ញុំមានការតក់ស្លុតចំពោះការធ្វើឃាតបងប្រុសរ៉ូហ្សេក្នុងអគារតៃហ្សេ ដែលជាកន្លែងសន្តិភាពនៅលើលោក"។ កញ្ញាម៉ៅ ស្រីកែវបានឱ្យដឹងថា នាងចាប់អារម្មណ៍ទៅលើការអធិដ្ឋានដែលខុសប្លែកពីព្រះសហគមន៍កម្ពុជា។ នៅប្រទេសយើង ការអធិដ្ឋានតែម្តងក្នុងមួយថ្ងៃ ឯនៅតៃហ្សេ គេធ្វើបីដងក្នុងមួយថ្ងៃ។ ក្រុមយុវជនខ្មែរក៏បាននាំយករូបភាពព្រះសហគមន៍កម្ពុជា និងសម្លៀកបំពាក់ប្រពៃណីខ្មែរទៅបង្ហាញនៅតៃហ្សេផងដែរ។ គន្ធា

# ព្រះសហគមន៍មានជីវិត



Photo: L. Sovanna

"ការចុះសួរសុខទុក្ខអ្នកជំងឺ គឺកើតចេញពីជំនឿ និងពីទឹកចិត្តអាណិតមេត្តារបស់យើង"។ ទាំងនេះគឺជាសំដីរបស់អ្នកស្រីជា សុខនី គ្រីស្តបរិស័ទនៃព្រះសហគមន៍រតនគីរី។ អ្នកស្រីបន្តទៀតថា: "ការសួរសុខទុក្ខបងប្អូន ដែលមានទុក្ខព្រួយ គឺជាការជួយសម្រាលបន្ទុកខាងផ្លូវចិត្ត ដើម្បីឱ្យគេមានក្តីសង្ឃឹមឡើងវិញ"។ ព្រះយេស៊ូយាងមកដើម្បីសង្គ្រោះមនុស្សគ្រប់ជាតិសាសន៍ ដោយមិនបានរើសអើងឡើយ។ គ្រប់ៗគ្នាសុទ្ធតែទទួលនូវការសង្គ្រោះពីព្រះអង្គ ដូចគ្នាទាំងអស់។ ព្រះសហគមន៍រតនគីរីស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជា ក្នុងតំបន់ដាច់ស្រយាល ដែលកម្រមានបងប្អូនទៅមកងាយស្រួលឡើយ។ ព្រះសហគមន៍នេះមានកំណើតប្រហែលជាក្នុងឆ្នាំ១៩៩៥។ សព្វថ្ងៃ មានគ្រីស្តបរិស័ទប្រមាណជា ២០គ្រួសារ។ លី សុវណ្ណា

# ប្រតិទិនថ្មីត្រូវចេញផ្សាយ

## មណ្ឌលវប្បធម៌កាតូលិក កម្ពុជា ទើបបានបោះពុម្ពប្រតិទិនឆ្នាំ "ខ" សម្រាប់ប្រើនៅក្នុងព្រះសហគមន៍ទាំងបីភូមិភាគ។

## ការលះបង់ខ្លួនដើម្បីអ្នកដទៃ

យុវនិស្សិតកាតូលិក ប្រមាណជា ៦៧នាក់ បានមកជួបជុំគ្នានៅព្រះសហគមន៍កំពង់សោម ដើម្បីចូលរួមក្នុងសិក្ខាសាលាដែលមានរយៈពេល ២ថ្ងៃ ក្រោមការដឹកនាំរបស់លោកឪពុកអាស្លី ដែលប្រធានបទលើកឡើងក្នុងអង្គសិក្ខាសាលានោះគឺ "តើមានអ្វីកើតឡើងពេលយើងស្រលាញ់អ្នកដទៃ?"។ លោកបូជាចារ្យរូបនេះក៏បានពន្យល់អំពីគោលដៅក្នុងសិក្ខាសាលានេះថា: "នេះគឺដើម្បីឱ្យយុវនិស្សិតទាំងនេះមានទំនាក់ទំនងជាមួយគ្នា និងដើម្បីឱ្យយុវជនយល់ផងដែរអំពីសេចក្តីស្រលាញ់ ដែលកំពុងមានការរីកចំរើន" ដោយការលះបង់ខ្លួនឯងទៅជួយអ្នកក្រីក្រ។ លោកបន្តទៀតថា ការជួយអ្នកក្រីក្រនេះ គឺធ្វើឱ្យយុវជនមានកម្លាំង និងមានការយកចិត្តទុកដាក់យ៉ាងខ្លាំង ពីព្រោះថាវាជាចំណាប់អារម្មណ៍របស់ពួកគេស្រាប់។
សិក្ខាសាលាក៏បានរិះគិតអំពីដំណើរជីវិតរបស់សន្តវ៉ាំងសង់ដឺប៉ូល ដែលលះបង់ខ្លួនដើម្បីអ្នកដទៃ។ ចុងបញ្ចប់ ដំណើរនៃអង្គសិក្ខាសាលាត្រូវបានប្រព្រឹត្តទៅយ៉ាងជោគជ័យ ដោយមានយុវនិស្សិតមួយចំនួនស្ម័គ្រចិត្តចូលរួមក្នុងក្រុមសន្តវ៉ាំងសង់ដឺប៉ូល ដើម្បីបម្រើបងប្អូនអ្នកក្រីក្រស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់នៃយើង។ លី សុវណ្ណា







Photo: DR

## ពិធីតែងតាំង

អបអរសាទរក្នុងពិធីតែងតាំង លោកអេវ៉ាន់ និងយ៉ូហាន ជាបូជាចារ្យក្រុមសាសនទូតយ៉ារូម៉ាលក្រៅប្រទេសកូឡុំប៊ី កាលពីថ្ងៃទី៦ វិច្ឆិកា ឆ្នាំ២០០៥ នៅប្រទេសកូឡុំប៊ី។ សូមព្រះជាម្ចាស់ប្រទានពរដល់លោកទាំងពីរផង !



## "ស្វែងរក" គឺជាឈ្មោះកាសែតប្រចាំសប្តាហ៍ចេញថ្មី សម្រាប់ចែកចាយឱ្យដល់និស្សិត និងមានលក់តាមតូបកាសែត។



## បណ្ណាល័យថ្មីក្នុងពន្ធនាគារកំពង់ចាម

ចាប់តាំងពីថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០០៥ បណ្ណាល័យដាក់សៀវភៅមួយត្រូវបានបើកឱ្យប្រើប្រាស់សម្រាប់អ្នកទោសនៅក្នុងពន្ធនាគារខេត្តកំពង់ចាមក្រោមការជួយឧបត្ថម្ភពីព្រះសហគមន៍កាតូលិក។ លោកបូជាចារ្យ សេវ៉ាលដ៏ រ៉ូសាំង ជាអ្នកទទួលខុសត្រូវក្នុងព្រះសហគមន៍តំបន់កំពង់ចាម បានមានប្រសាសន៍ថា មនុស្សណាៗ ក៏សុទ្ធសឹងតែមានតម្លៃរបស់គេដែរ។

## ទស្សនាព្រះសហគមន៍មណ្ឌលគីរី

ពីថ្ងៃទី២៨ តុលា ដល់ ០១ វិច្ឆិកា ក្រុមយុវជនបឹងទំពុនចំនួន ២០នាក់ បានធ្វើដំណើរទស្សនកិច្ចសួរសុខទុក្ខគ្រីស្តបរិស័ទជនជាតិភាគតិចនៅព្រះសហគមន៍ដាក់ដាំ និងប៊ូស្រានៅខេត្តមណ្ឌលគីរី ដឹកនាំដោយលោកបូជា-ចារ្យម៉ារីយ៉ូ ហ្គេហ្សិ។ កញ្ញាគុយ វី ជាយុវនារីម្នាក់បាននិយាយ ថា: "ខ្ញុំពិតជាសប្បាយមែនទែនពេលឃើញអំពីស្ថានភាពជាក់ស្តែងរបស់ប្រជាជន ទោះបីជាពួកគេមានភាពលំបាក ប៉ុន្តែជំនឿរបស់គេនៅតែរឹងមាំជាងរូបខ្ញុំ"។

## សមិទ្ធិព្រះសហ-គមន៍ថ្មីមួយទៀត

សាលាប្រជុំថ្មីមួយត្រូវបានកសាងឡើងនៅព្រះសហ-គមន៍កំពង់សោម ដើម្បីទទួលយុវជន យុវនារី ឬបងប្អូនគ្រីស្តបរិស័ទផ្សេងៗទៀត ដែលអាចមកធ្វើជាអង្គសន្និបាត ឬសំណាក់ធម៌ជាក្រុមៗ និងសម្រាប់គ្រីស្តបរិស័ទ នៅទីនោះជួបជុំគ្នាធ្វើពិធីបុណ្យធំៗផងដែ។ សាលានេះអាចទទួលមនុស្សបានពី ១០០ នាក់ដល់ ៣០០នាក់។ ការកសាងត្រូវចំណាយអស់ទឹកប្រាក់ប្រមាណជាង ២៥០០$ អាមេរិក។

ជុំវិញ



Photo: DR

# មរណភាពអ្នកស្រី Parks

នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៥៥ អ្នកស្រី រ៉ូហ្សា លី ប៉ាកស៍ (Rosa Lee Parks) បាននិយាយថា: "ទេ! ទេ!" នៅពេលដែលគេសុំឱ្យគាត់ងើបឈរដើម្បីប្រគល់កន្លែង ដែលគាត់អង្គុយឱ្យទៅបុរសស្បែកសម្នាក់នៅក្នុងរថយន្តក្រុងមួយ។ ការបដិសេធរបស់គាត់គឺជាការរំលោភលើច្បាប់ក្នុងតំបន់នៃរដ្ឋ អាឡាបាម៉ា សហរដ្ឋអាមេរិក ដែលមានភាពរើសអើងជាតិសាសន៍។ ភ្លាមនោះ អ្នកស្រី រ៉ូហ្សា លី ប៉ាកស៍ ត្រូវគេឃាត់ខ្លួន និងត្រូវទទួលរងការផាកពិន័យ ១៥$។ ប៉ុន្មានឆ្នាំក្រោយមក អ្នកស្រី រ៉ូហ្សា លី ប៉ាកស៍ បានលើកឡើងថា: "ខ្ញុំនឿយហត់នឹងការព្រមចុះញ៉ម។ ខ្ញុំមានការធុញទ្រាន់ល្មមគ្រប់គ្រាន់ហើយ ដោយតែងតែគោរពតាម និងមិនដែលតបតទៅនឹងច្បាប់បង្គាប់របស់ជនជាតិស្បែកសនោះ"។
ក្រោយមក យុវជនអ្នកដឹកនាំវ័យក្មេងម្នាក់នៅក្នុងទីក្រុងមួយនៃសហរដ្ឋអាមេរិក បានដឹកនាំចលនាសាមគ្គីភាពដ៏ធំមួយ។ អំឡុងពេល ៣៨០ថ្ងៃ រថយន្តទាំងឡាយនៅក្នុងទីក្រុងត្រូវបានជនជាតិស្បែកខ្មៅធ្វើពលិការមិនឡើងជិះ។ នៅឆ្នាំ១៩៥៨ ម៉ាតាំង លូថេ គីង (Martin Luther King) បានកត់សម្គាល់ថា "ការឃាត់ខ្លួនអ្នកស្រី រ៉ូហ្សា លី ប៉ាកស៍ គឺជាកត្តាជំរុញឱ្យមានការឈឺចាប់នៅពេលក្រោយមក"។ ចលនាប្រកបដោយភាពអហិង្សាប្រឆាំងនឹងការរើសអើងនេះ បានធ្វើឱ្យមានការទទួលស្គាល់នៃសិទ្ធិសាធារណៈរបស់ជនជាតិស្បែកខ្មៅ។ មួយឆ្នាំក្រោយមក គឺនៅថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ១៩៥៦ តុលាការកំពូលបានប្រកាសនៅក្នុងរដ្ឋធម្មនុញ្ញដោយប្រឆាំងទៅនឹងការរើសអើងប្រកាន់ពណ៌សម្បុរ។ P.R

# ការជូនកាដូគឺជាកាយវិការនៃក្ដីស្រលាញ់

**តើនៅថ្ងៃបុណ្យណូអែល អ្នកមានអ្វីខ្លះជូនដល់អ្នកជាទីស្រលាញ់? អ្នកមិនគួរធ្វើឱ្យថ្ងៃដ៏ពិសេសនេះរំលងផុតទៅបានទេ សម្រាប់ការជូនកាដូទៅដល់ឪពុកម្ដាយ មិត្តភ័ក្ដិ ឬមនុស្សពិសេស ដើម្បីសម្ដែងការដឹងគុណ សេចក្ដីស្រលាញ់ និងរឹតចំណងទាក់ទងរវាងគ្នា និងគ្នាឱ្យកាន់តែរឹងមាំ។ តើថ្ងៃនោះមានអត្ថន័យសំខាន់យ៉ាងណាទៅហ្ន៎?**

ថ្ងៃទី២៥ ធ្នូ ជាថ្ងៃមួយ ដែលព្រះយេស៊ូទ្រង់យាងមកប្រសូតជាមនុស្សលោក ដើម្បីធ្វើការសង្គ្រោះអស់អ្នកដែលមានបាប។ ក្នុងថ្ងៃនោះដែរ យុវជនយុវនារីនាំគ្នាចូលរួមអបអរសាទរដោយមានអ្នកខ្លះទិញកាដូជូនដល់មនុស្សដែលខ្លួនស្រឡាញ់ផងដែរ ដូចជា ឪពុកម្ដាយ មិត្តភ័ក្ដិ សង្សារ ឬក៏បងប្អូនជាដើម។ ការជូនអ្វីមួយនោះ ទោះបីជាតិចក្ដីច្រើនក្ដី វាគឺជាសញ្ញាមួយបង្ហាញពីសន្ដានចិត្ត និងសេចក្ដីពេញចិត្ត ក្នុងការចងចំណងនៃក្ដីស្រលាញ់ និងមិត្តភាពជាមួយអ្នកនោះទៅថ្ងៃខាងមុខ។

កញ្ញាផាន់ ណារី ជាគ្រីស្ដបរិស័ទកាតូលិកមួយរូប និងកំពុងត្រៀមលក្ខណៈទិញកាដូជូនដល់មិត្តភ័ក្ដិ ដើម្បីបង្កើននូវភាពសប្បាយរីករាយ និយាយថា: "កាដូដែលខ្ញុំទិញឱ្យ មិត្តភ័ក្ដិ ឪពុកម្ដាយ និងបងប្អូនរបស់ខ្ញុំ គឺវាមានអត្ថន័យណាស់ សម្រាប់រូបខ្ញុំ ព្រោះថាខ្ញុំបានធ្វើឱ្យពួកគេរីករាយ និងចូលរួមជាមួយនិងការធ្វើពិធីបុណ្យជាទីសោមនស្សនេះ"។

លោកផាន់ សុភារ៉ា គ្រូបង្រៀននៃសាកលវិទ្យាល័យន័រតុនក៏បានឱ្យដឹងនូវអារម្មណ៍លោកដែរថា លោកមានចំណាប់អារម្មណ៍ទៅលើការជូនកាដូឱ្យគ្នាទៅវិញទៅមកនារដូវបុណ្យណូអែល ដែលនេះគឺជាឱកាសមួយបង្កើតនូវចំណងមិត្តភាពនឹងគ្នាមួយកម្រិតទៀត។ លោកបន្តថា: "សម្រាប់ខ្ញុំកាដូពេលនោះវាមានអត្ថន័យធំធេងណាស់ គឺទី១ ចំពោះមិត្តភ័ក្ដិ គឺជាសញ្ញាមួយបង្ហាញអំពីការរឹតចំណងមិត្តភាពឱ្យបានកាន់តែកក់ក្ដៅ និងកាន់តែរឹងមាំ។ ទី២ ចំពោះដៃគូស្នេហាគឺការជូនកាដូនេះ វាបង្ហាញអំពីចិត្តស្មោះត្រង់របស់យើង និងបង្កើននូវការស្រលាញ់កាន់តែខ្លាំងឡើងចំពោះគ្នា"។

ចំពោះចំណុចនេះ លោកអភិបាល អង់តូនី ក៏មានប្រសាសន៍ឱ្យដឹងផងដែរថា ការជូនកាដូឱ្យគ្នាទៅវិញទៅមក ជារបៀបមួយ ដែលព្រះជាម្ចាស់បានផ្ញើព្រះបុត្រារបស់ព្រះអង្គមកឱ្យយើង។ យើងពុំអាចធ្វើទង្វើ ឱ្យស្មើនឹងព្រះជាម្ចាស់បានទេ ប៉ុន្តែគឺគ្រាន់តែជាអត្ថន័យ នៃបុណ្យណូអែល។ យើងធ្វើការបូជាជីវិតខ្លួនយើង ដើម្បីព្រះរូម ឬដើម្បីព្រះអ្នកដទៃ។ ប៉ុន្តែវាជារបៀបដែលគេចាប់ផ្ដើមពីអ្វីដែលគេមាន គេសូមយកចែកជារង្វាន់ ចែកកាដូ ដើម្បីបង្ហាញពីសេចក្ដីស្រលាញ់រាល់អ្នក ដែលខ្វះខាត។ យូរៗទៅ មិត្តសំលាញ់ សមាជិកក្នុងក្រុមគ្រួសារនិយាយប្លែកៗ ដូចជា របៀបស្រលាញ់គ្នាទៅវិញទៅមក ឬក៏របៀបលេងល្បែងសប្បាយៗ



Photo: M. Kunthear

ការជូនកាដូគឺជាផ្នែកមួយនៃសន្ដានចិត្តចង់ចងមិត្តជានិច្ច

រវាងគ្នានិងគ្នា ប៉ុន្តែ ចំពោះអត្ថន័យជារួមនោះ គឺថាយើងបូជាខ្លួនយើងចំពោះប្រយោជន៍រួមគ្នា ឬសម្រាប់ប្រយោជន៍អ្នកដទៃ។ លោកឪពុកបន្ថែមទៀតថា ការជូនកាដូឱ្យគ្នាទៅវិញទៅមក វាមានសារៈសំខាន់ណាស់ដូចជាព្រះជាម្ចាស់ប្រទានព្រះបុត្រាមកឱ្យយើង គឺបូជាខ្លួនឯង ដែលជាសេចក្ដីស្រលាញ់។ ប៉ុន្តែឥឡូវនេះ យើងឃើញមាននៅកន្លែងផ្សេងៗ នៅពេលបុណ្យណូអែល គេឃើញមានតុបតែងពន្លឺស្អាតៗ មានរបៀបតុបតែង នេះវាដូចជាការផ្សាយពាណិជ្ជកម្មយ៉ាងសម្រាប់លក់ដូរអីវ៉ាន់ផ្សេងៗ។ លោកយល់ថា វាគឺគ្រាន់តែជាម៉ូដ វាមិនសូវទាក់ទងនឹងរឿងជំនឿទេ ពីព្រោះភាគច្រើនមិនមែនជាគ្រីស្ដបរិស័ទ គឺសាសនាណាក៏បាន គេគ្រាន់តែចូលរួមសប្បាយ ដោយការឱ្យកាដូ ឬរបស់ផ្សេងៗ ដែលនេះជាការចូលចិត្ត ការរាប់អាន សួរសុខទុក្ខគ្នា ឬជូនពរគ្នា។

កញ្ញាលី ទីម ដែលជាគ្រីស្ដបរិស័ទ និងជាបុគ្គលិករបស់ CDRI បាននិយាយថា នាងមិនទាន់បានគិតពីការទិញកាដូនៅឡើយទេ។ នាងបន្តថា បុណ្យនេះធ្វើឱ្យនាងសប្បាយរីករាយ និងអាចបង្កើតនូវមិត្តភាព កាន់តែស្និទ្ធស្នាលខ្លាំងឡើង។ នាងធ្លាប់ឮគ្រូ និងចាស់ៗមួយចំនួនធ្វើការរិះគន់ថា វាគ្មានប្រយោជន៍អ្វីដែលធ្វើបុណ្យនេះ ព្រោះវាចំណាយលុយឥតប្រយោជន៍ និងពុំមែនជាប្រពៃណីខ្មែរ។ ប៉ុន្តែ នាងគិតថា នេះជាបុណ្យមួយប្រពៃសម្រាប់ចងមិត្ត និងបង្ហាញអំពីសេចក្ដីស្រលាញ់។

## តើហេតុអ្វីប្រារព្ធធ្វើថ្ងៃទី២៥ ធ្នូ?

តាមអត្ថន័យព្រះគម្ពីរថ្ងៃទី២៤ មិថុនា ជាថ្ងៃដែលលោកយ៉ូហានបាទីស្ដ ប្រកាសជាផ្លូវការថា: "ព្រះយេស៊ូ ! ព្រះអង្គនឹងចម្រើនឡើងទៅៗ ហើយខ្លួនលោកផ្ទាល់នឹងទាបទៅៗ"។ នេះគឺជារបៀបលោកប្រកាសរៀបចំផ្លូវដល់ព្រះគ្រីស្ដ។ ដូច្នេះព្រះសហគមន៍ចាត់ទុកថាថ្ងៃ២៤ ខែមិថុនា ជាបុណ្យគោរពលោកយ៉ូហានបាទីស្ដ និងថ្ងៃ២៤ ខែធ្នូ យប់ គឺជាបុណ្យព្រះយេស៊ូប្រសូត។

## តើអ្វីទៅជាថ្ងៃ បុណ្យព្រះយេស៊ូប្រសូត?



Photo: S. Metrey

លោកអភិបាលអង់តូនី មានប្រសាសន៍ថា បើតាមរយៈអរិយធម៌ ភាសា និងសាសនាផ្សេងៗ នៅបណ្ដាប្រទេស ដែលគ្រីស្ដសាសនាមានការរីកចំរើន យើងប្រទះឃើញមានបុណ្យ ១ ផ្សេងតាមអរិយធម៌ដើមរបស់គេ ដែលជាបុណ្យគោរពព្រះអាទិត្យ។ ឃើញថា បុណ្យគោរពព្រះអាទិត្យជាបុណ្យមួយល្អ ព្រោះយើងទទួលស្គាល់ថា ព្រះគ្រីស្ដជាព្រះអាទិត្យពិតមែន ពីព្រោះព្រះជាអម្ចាស់ បានបង្កើតព្រះអាទិត្យឡើង។ គេចង់យកបុណ្យព្រះអាទិត្យ ជាបុណ្យគោរពព្រះយេស៊ូគ្រីស្ដ ដែលជាព្រះដ៏ពិតប្រាកដ។ ឥឡូវបុណ្យនេះត្រូវបានដូរឈ្មោះ និងប្រើមកជាបុណ្យព្រះយេស៊ូប្រសូត ឬក៏ជាបុណ្យណូអែលវិញ។

លោកឪពុកមានប្រសាសន៍ទៀតថា ចំណុចមួយទៀត ព្រះយេស៊ូប្រសូត នៅស្រុកលោកយ៉ូសែប ភូមិបេថ្លេហិម ដែលសព្វថ្ងៃជាប្រទេសប៉ាឡេស្ទីន ប៉ុន្តែ គ្មាននរណាដឹងថា ថ្ងៃណា? ខែណា? ដែលព្រះយេស៊ូប្រសូតទេ សូម្បីតែអ្នកស្រាវជ្រាវក៏រកភស្ដុតាងបញ្ជាក់ពុំឃើញផងដែរ។

ដូច្នេះ គេក៏មានវិធីដើម្បីជ្រើសរើសថ្ងៃមួយ តាមបុណ្យគោរពព្រះអាទិត្យ គឺនៅខែធ្នូ ទី២៣ ដែលយប់ និងថ្ងៃប្រៀបធៀបគ្នា គឺយប់វែងជាងថ្ងៃ។ ដោយសារនេះជារបៀបដែលថ្ងៃ និងយប់ខុសគ្នាទៅតាមរដូវរបស់យើង ដូចជានៅរដូវក្ដៅថ្ងៃវែងជាង ឯរដូវត្រជាក់ យប់វែងជាង។ ប៉ុន្តែចាប់ពីថ្ងៃនោះយើងមានថ្ងៃកាន់តែវែងទៅៗបង្ហាញថាព្រះយេស៊ូប្រសូត គឺជាព្រះអាទិត្យ ពិតប្រាកដហើយ បុណ្យណូអែល មានន័យថា ចាប់ពីថ្ងៃបុណ្យទៅមានព្រះអាទិត្យកាន់តែវែងទៅៗ ឬក៏រយៈពេលរបស់ថ្ងៃវែងទៅៗ។ ដូច្នេះ ហើយគេទទួលស្គាល់ថា នេះជារបៀបដែលព្រះយេស៊ូប្រសូតហើយ។

រីឯលោកឪពុកអ៊ុន សុនយល់ឃើញថា: "ណូអែលជាថ្ងៃ ដែលព្រះជាម្ចាស់បានចាត់ព្រះបុត្រាឱ្យមកប្រសូតជាមនុស្ស ដើម្បីមនុស្សអាចកើត ក្នុងព្រះជាម្ចាស់តាមសន្ដអៀរ៉ាណេ។ អត្ថន័យមួយទៀតគឺព្រះជាម្ចាស់គង់ជាមួយយើង "អេម៉ាណូអែល" បើព្រះអង្គ មិនប្រសូតមកជាមនុស្សទេ មនុស្សក៏មិនអាចទៅរកព្រះអង្គបានដែរ។

អត្ថបទដោយមុំ គន្ធា

## អាជីវកម្មណូអែល



Photo: M. Kunthear

យ៉ាងហោចណាស់ ក៏ត្រូវត្រៀមលក្ខណៈមុនរយៈពេល ១ខែដែរ សម្រាប់ អ្នកលក់វត្ថុអនុស្សាវរីយ៍ផ្សេងៗក្នុងការកក់ទុកនូវរបស់សំខាន់ៗ ដែលនឹងត្រូវដាក់លក់នាឱកាសបុណ្យណូអែល។

កញ្ញា សាយ័ណ្ណ ម្ចាស់ហាងលក់វត្ថុអនុស្សាវរីយ៍ ណៃស៍ បាននិយាយឱ្យដឹងថា ហាងរបស់នាងមានភាពមមាញឹកខ្លាំងក្នុងថ្ងៃបុណ្យណូអែល និងអាចរកចំណូលបានលើសពីថ្ងៃធម្មតា និងថ្ងៃបុណ្យពិសេសផ្សេងៗទៀត។ នាងបន្តថា សម្រាប់អតិថិជនរបស់នាងក្នុងថ្ងៃនោះ ភាគច្រើន គឺជាយុវវ័យ និងសិស្សានុសិស្ស។ នាងបញ្ជាក់បន្ថែមទៀតថា អីវ៉ាន់ដែលមាននៅហាងណៃស៍ គឺម្ដាយនាងបាននាំមកពីប្រទេសថៃ និងខុសប្លែកៗពីគ្នា ដោយពុំដែលឱ្យមានរបស់ណាដូចគេនោះទេ។

លោកហ៊ុន រដ្ឋា ដែលជាបុគ្គលិកនៃក្រុមហ៊ុនទេសចរណ៍មួយ បាននិយាយថា: "ខ្ញុំគិតថាថ្ងៃបុណ្យណូអែល គឺជាថ្ងៃសំខាន់សម្រាប់អាជីវកររកចំនូលបានបន្ថែមលើសពីថ្ងៃធម្មតា" ។

## សេចក្ដីជូនដំណឹង!

អ្នកនាំសារ សូមអញ្ជើញលោកបូជាចារ្យ បងប្រុស បងស្រី និងគ្រីស្ដបរិស័ទគ្រប់ភូមិភាគផ្ញើនូវរូបថត ឬ CD រូបថត អំពីអភិបូជា ការលេងល្បែងកំសាន្ដ ឬអំពីសកម្មភាពផ្សេងៗ នៅរដូវបុណ្យព្រះយេស៊ូប្រសូតមកកាន់ការិយាល័យ អ្នកនាំសារនៅភ្នំពេញ ក្នុងគោលបំណងធ្វើទំព័ររូបថតអំពីបុណ្យព្រះយេស៊ូប្រសូតក្នុង អ្នកនាំសារ លេខក្រោយដើម្បីបង្ហាញនូវសកម្មភាពព្រះសហគមន៍។ សូមផ្ញើឱ្យបានរហ័សបំផុត គួរតែមុនថ្ងៃទី១ មករា ២០០៥។ សូមអរគុណ!

ក្រុមលោកអភិបាលឡាវ និងកម្ពុជាចំនួន ៨រូប បានជួបប្រជុំប្រចាំឆ្នាំរបស់ខ្លួន ដើម្បីចែកបទពិសោធន៍ ការសហការ ស្វែងរកវិធីសាស្ត្រលើការអប់រំជំនឿការអប់រំនិស្សិតទេវវិទ្យាល័យ និងអ្នកស្វែងយល់អំពីការត្រាស់ហៅរបស់ព្រះជាម្ចាស់។

# ជំនួបរវាងលោកអភិបាលឡាវ-ខ្មែរ



ការថតរូបអនុស្សាវរីយ៍របស់ក្រុមលោកអភិបាលខ្មែរ និងឡាវនៅពេលសម្រាក

ពីថ្ងៃទី៧ ដល់ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៥ កន្លងទៅនេះ ក្រុមលោកអភិបាលព្រះសហគមន៍ឡាវ និងកម្ពុជា បានមកជួបប្រជុំគ្នានៅទីក្រុងព្រះសីហនុ ដើម្បីធ្វើការចែករំលែកនូវបទពិសោធន៍នៃសកម្មភាព ដែលបានធ្វើកន្លងមក និងរាយការណ៍ពីការរីកចម្រើននៃព្រះសហគមន៍នីមួយៗ ព្រមទាំងឧបសគ្គទាំងឡាយ ដែលបានជួបប្រទះផងដែរ។

លោកអភិបាល យ៉ូហាន ខាំសេ វិចាវង្ស ជាប្រធាននៃក្រុមលោកអភិបាលប្រទេសទាំងពីរ បានមានប្រសាសន៍ថា: "ជាការសំខាន់ណាស់ ដែលលោកអភិបាល របស់ព្រះសហគមន៍នីមួយៗ មកធ្វើការចែករំលែកនូវសេចក្ដីពិតរួមគ្នា" ពីព្រោះយើងគឺជាបងប្អូននឹងគ្នា ដែលមានព្រះជាម្ចាស់តែមួយ។

បន្ទាប់ពីបានយល់ស្របលើចំនុចនេះ លោកអភិបាលអេមីល ដេតម្យ ដែលជាអភិបាលភូមិភាគភ្នំពេញ និងជាអគ្គលេខាធិការក្រុម បានគូសបញ្ជាក់ថា: "នេះគឺជាកម្មវិធីដ៏ល្អដើម្បីយើងលើកទឹកចិត្តគ្នាទៅវិញទៅមក ឱ្យបន្តបេសកកម្ម និងរកផ្លូវបម្រើព្រះសហគមន៍ឱ្យប្រសើរជាងនេះ"។ រីឯលោកអភិបាលយ៉ូហាន បានបន្ថែមថា: "អ្នកខ្លះយល់ថា អង្គប្រជុំនេះ ហាក់ដូចជាពុំសូវមានសារៈសំខាន់ប៉ុន្មានទេ ដោយសារគេមើលឃើញថា ស្ថានភាពរបស់ប្រទេសទាំងពីរ គឺប្រហាក់ប្រហែលគ្នា តែស្ថានភាពពិតគឺវាខុសគ្នាទាំងស្រុង"។ លោកបន្តថា: "ព្រះសហគមន៍កម្ពុជាអាចធ្វើសកម្មភាពការងារជារបៀបផ្សេងៗបាន។ ប៉ុន្តែ ព្រះសហគមន៍ឡាវវិញ មិនអាចធ្វើសកម្មភាពអ្វីធំដុំបានឡើយ ដោយសារស្ថានភាពនយោបាយមិនអនុញ្ញាត។ នៅប្រទេសឡាវ ក្រុមសាសនទូតបរទេសមិនត្រូវបានអនុញ្ញាតឱ្យចូលក្នុងប្រទេសឡើយ"។

តាមរយៈស្ថានភាពនៃព្រះសហគមន៍ឡាវ លោកអភិបាលគីតេ បានចាប់អារម្មណ៍ថា: "ឧបសគ្គរបស់ឡាវ ធ្វើឱ្យយើងចេះត្រៀមខ្លួនប្រឈមមុខចំពោះពេលវេលាលំបាក"។ នៅថ្ងៃបញ្ចប់ លោកអគ្គរាជទូតរបស់សម្ដេចប៉ាប ពេណ្ណាស៊ីអូ ក៏បានអញ្ជើញចូលរួមបិទអង្គសន្និបាត ដែលជាសញ្ញាមួយដ៏ប្រសើរដើម្បីជាការលើកទឹកចិត្តដល់ក្រុមអភិបាលទាំងអស់ឱ្យបន្តបេសកកម្មបម្រើព្រះជាម្ចាស់ដោយអំណរផងដែរ។

## ប្រវត្តិក្រុម

ក្រុមអភិបាលនៃព្រះសហគមន៍ឡាវ និងកម្ពុជា ត្រូវបានតែងតាំងឡើងក្រោយមហាសន្និបាតបុរីវ៉ាទីកង់ ទី២។ នៅឆ្នាំ១៩៧៥ មានអភិបាល ៧រូប។ នៅឆ្នាំ២០០០ មានសមាជិក ៨រូប។ អាណត្តិក្រុមគឺ ៣ឆ្នាំម្ដង។ អាណត្តិនេះមានលោកអភិបាលអេមីល ជាប្រធាន និងលោក លូអ៊ី ម៉ារីលីញ (ឡាវ) គឺជាអគ្គលេខាធិការ។

## ពិធីបុណ្យព្រះយេស៊ូប្រសូតនៅព្រះសហគមន៍ឡាវ

ពិធីបុណ្យព្រះយេស៊ូប្រសូតគឺជាពេលវេលាដ៏រីករាយមួយ។ ព្រះជាម្ចាស់យាងមកយកកំណើតជាមនុស្សដើម្បីផ្ដល់នូវក្ដីសង្ឃឹមអំណរសប្បាយដល់មនុស្សទាំងអស់។

ការប្រារព្ធពិធីនៅតាមប្រទេស ឬក្នុងព្រះសហគមន៍នីមួយៗ មានលក្ខណៈមិនដូចគ្នានោះទេ។ ជាក់ស្ដែង ចំពោះព្រះសហគមន៍ឡាវ លោកអភិបាល លូអ៊ី ម៉ារីលីញ ម៉ងខាណោឃួន មកពីភូមិភាគប៉ាកសេ បានមានប្រសាសន៍ថា: "ការប្រារព្ធបុណ្យនៅព្រះសហគមន៍ឡាវគឺថាយើងព្យាយាមបញ្ចូលឱ្យមានលក្ខណៈជាឡាវ។ ប៉ុន្តែការប្រើនូវរូប សំណាកផ្សេងៗ គឺតាមរបៀបលោកខាងលិច"។ លោកអភិបាលរូបនេះ ក៏បន្តទៀតថា: "យើងអាចប្រារព្ធ នៅគ្រប់ទីកន្លែងតាមព្រះសហគមន៍មួយៗ ដោយចាក់ចម្រៀង ឬច្រៀងបទគ្រីស្ដម៉ាស់។ កន្លែងខ្លះមានសម្ដែងអំពីកំណើតព្រះយេស៊ូផងដែរ។

អត្ថបទដោយ លី សុវណ្ណា





# តើទំនាក់ទំនងយ៉ាងម៉េចឱ្យបានល្អ?

ពេលខ្លះការទំនាក់ទំនងរវាងមនុស្សផងគ្នាមិនមានលក្ខណៈងាយស្រួលប៉ុន្មានទេ។ តើធ្វើដូចម្ដេចអាចដោះស្រាយបញ្ហាទាំងឡាយឱ្យមានភាពប្រក្រតី? អ្នកនាំសារសូមបង្ហាញបញ្ហារបស់យុវជនមួយចំនួនដោយមានអ្នកផ្ដល់ប្រឹក្សាមកចូលរួមដោះស្រាយ។



រូបលំអ: មិត្តភាពគឺជាការយោគយល់គ្នាទៅវិញទៅមកដើម្បីបង្កើតនូវស្នាមញញឹមទាំងអស់គ្នា

**តើធ្វើយ៉ាងណាដើម្បីឱ្យការឈឺចាប់មានរយៈពេលខ្លី ?**
លោកសំណាងមានបញ្ហាផ្លូវចិត្ត ដោយសារនារី ដែលលោកស្រឡាញ់ អស់រយៈពេល ៦ឆ្នាំ បានរៀបការចោលលោក។ លោកសំណាងមានការពិបាកចិត្តខ្លាំងណាស់រហូតដល់លោកស្រក់ទឹកភ្នែកចេញមក។ លោកចង់សួរថា: តើត្រឹមត្រូវដែរឬទេ ដែលលោកបានកាត់ចិត្តដោយគិតថា នាងរៀបការនេះដោយសារតែនាងឈប់ស្រលាញ់រូបលោកហើយនោះ?

**លោកសាស្ត្រាចារ្យចិត្តវិទ្យា ផាន់ ចាន់ពៅ:** ដំណោះស្រាយរបស់លោកសំណាង គឺពិតជាត្រឹមត្រូវណាស់ពីព្រោះដៃគូរបស់គាត់បានរៀបការរួចទៅហើយ។ យើងពុំអាចដើរតួជាអ្នកទីបីបំផ្លាញនូវស្នេហាថ្មីរបស់គេដទៃបានទេ សុខចិត្តឈឺចាប់រយៈពេលខ្លីប្រសើរជាងការឈឺចាប់រយៈពេលយូរ។ ដើម្បីឱ្យការឈឺចាប់ឆាប់សាបរលាបវិញនោះ ត្រូវតែគិតថានៅមាននារីជាច្រើនទៀត ដែលចង់បានស្នេហា ដ៏ពិតប្រាកដមួយ ហើយគិតថា នេះពុំមែនជាគូយើង។ យើងគួរទៅរកគូដ៏ពិតប្រាកដរបស់យើង។ ម្យ៉ាងទៀត គឺត្រូវខិតខំរៀនសូត្រក្រេបយកចំណេះដឹង រកការងារធ្វើដើម្បីទទួលបាននូវប្រាក់បៀវត្សរ៍ រួចសឹមស្វែងរកនារីល្អម្នាក់ ដើម្បីរៀបការជាមួយកសាងគ្រួសារដ៏មានសុភមង្គលពេញមួយជីវិត។

**តើធ្វើយ៉ាងណាដើម្បីឱ្យមានការចុះសំរុងគ្នាឡើងវិញ ?**
ស៊ីថាមានមិត្តម្នាក់ ដែលមានអារម្មណ៍ខុសគ្នា ដោយមិត្តគេចូលចិត្តដើរលេងច្រើន ដែលផ្ទុយពីរូបគេ។ ស៊ីថាចង់ឱ្យមិត្តឈប់ដើរលេង ប៉ុន្តែមិត្តគេនោះមិនអាចធ្វើបាន ហើយក៏បានទៅសេពគប់ជាមួយមិត្តថ្មី។ ស៊ីថាមានចិត្តច្រណែន និងខឹងដោយសារតែមិត្តភ័ក្តិរបស់គេលែងនឹកនាដល់រូបគេ ដែលជាមិត្តចាស់ទៀតហើយ។ ស៊ីថាសួរថា តើធ្វើយ៉ាងណាដើម្បីឱ្យមានការយល់ចិត្តគ្នារវាងមិត្តគេ និងរូបគេ?

**លោកបូជាចារ្យ សេរ៉ាលដ៏:** អ្វីៗ ដែលយើងត្រូវយល់ក្នុងសេចក្ដីស្រលាញ់ គឺដំបូងត្រូវមានសេរីភាពចំពោះគ្នាទៅវិញទៅមក។ យើងមិនអាចបង្ខំនរណាម្នាក់ ឱ្យគេមកស្រលាញ់យើងបានទេ។ សេចក្ដីស្រលាញ់មួយដ៏ត្រឹមត្រូវនោះ វាគឺជាការស្រឡាញ់អ្នកដទៃ ដោយផ្ដល់នូវអ្វីៗ ដែលជាតម្រូវការ និងជាប្រយោជន៍សម្រាប់គេ។ យើងស្រលាញ់អ្នកដទៃ ក្នុងលក្ខណៈ គេជាមនុស្សខុសប្លែកពីយើង។ យើងត្រូវចេះចែកនូវពេលវេលាឱ្យគ្នាទៅវិញទៅមក ដើម្បីឱ្យការទំនាក់ទំនងរវាងភាគីទាំងពីរអាចរក្សានៅគង់វង្សដដែល។

**តើនាងត្រូវប្រឈមមុខនឹងអ្វីខ្លះទៅ ?**
ចន្ថា គឺជាក្មេងម្នាក់ ដែលទទួលរងការធ្វើបាបអំពីមីងនាង។ ទោះបីជានាងឈឺចាប់យ៉ាងណា ក៏នាងនៅតែខិតខំតស៊ូរៀនធ្វើការរកលុយឱ្យម្ដាយ និងមីង ដែលមីងគិតតែលេងល្បែង រីឯ ម្ដាយនាងគិតតែពីផឹកស្រា។ នាងក៏មានគំនិតចង់លោតទឹកសម្លាប់ខ្លួន។ នាងចង់ដឹងថា តើធ្វើយ៉ាងម៉េចដើម្បីធ្វើឱ្យម្ដាយ និងមីងរបស់នាងឈប់ផឹកស្រា និងលេងល្បែង?

**លោកសាស្ត្រាចារ្យផាន់ ចាន់ពៅ:** យើងអាចនិយាយជាមួយគាត់ ឱ្យពួកគាត់ចេះថែរក្សានូវសុខភាព ចេះស្រលាញ់ខ្លួនឯង និងគ្រួសារខ្លួនដើម្បីកសាងអនាគតគ្រួសារតទៅមុខទៀត។ ម្យ៉ាងយើងត្រូវរកមូលហេតុនៃការលេងល្បែង និងផឹកស្រារបស់ពួកគាត់ថា តើមកពីមូលហេតុអ្វី ?។

សម្រង់កម្មវិធីវិទ្យុ "យុវវ័យសម័យទំនើប"

## កម្មវិធីថ្មីនឹងរៀបចំបង្កើត

"អេម៉ាណូអែល"

"សម្លេងពីព្រះសហគមន៍កាតូលិក" ចំណងជើងកម្មវិធីវិទ្យុថ្មីរបស់ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក។ យើងមានរៀបចំកម្មវិធីធំៗចំនួន៤ ដូចជាដំណឹងល្អថ្ងៃអាទិត្យ ការឆ្លើយតបរបស់លោកបូជាចារ្យ ព័ត៌មានពីព្រះសហគមន៍ និងបញ្ហាទាក់ទងនឹងយុវវ័យ។ កម្មវិធីនេះនឹងមានផ្សាយក្នុងស្ថានីយវិទ្យុ FM 91.5 MHz នៅវេលាម៉ោង ៦:៣០-៧:០០ យប់ជារៀងរាល់ថ្ងៃសៅរ៍ នៅទីរួមខេត្តបាត់ដំបង។

## សូមប្រិយមិត្តកំសាន្តនឹងរឿងអំពីទេវតាតូចៗ មុនបុណ្យព្រះយេស៊ូប្រសូត




## ចូរកូនមើល!

រាត្រីស្ងាត់ឈឹង
រាត្រីងងឹតសូន្យសុង
រាត្រីគ្របដណ្តប់លើផែនដីទាំងមូល។



ចូរកូនមើល !
កូនក្មេងម្នាក់កើតឡើង ជាទារកដ៏តូចបំផុត
ផុយស្រួយណាស់ គ្មានអ្វីការពារសោះ
ប៉ុន្តែទារកដ៏តូចនេះបើកភ្នែកក្រឡង់
នៅពេលរាត្រី

នេះហើយជាព្រះអម្ចាស់
ជាព្រះជាម្ចាស់នៃយើង
ទារកដ៏តូចនេះជាពន្លឺ ដែលលេចចេញពី
ទីងងឹត បពិត្រព្រះយេស៊ូ !
យើងសូមច្រៀងលើកតម្កើងព្រះអង្គ។

ចូរកូនមើល !
ពេលព្រះអរុណរះឡើង
ពន្លឺចែងចាំងលើផែនពសុធា
ថ្ងៃនេះព្រះអម្ចាស់គង់នៅជាមួយយើង។

### រដូវរង់ចាំ

រដូវរង់ចាំមានរយៈពេល ៤សប្តាហ៍ មុនថ្ងៃបុណ្យព្រះយេស៊ូប្រសូត។ នៅថ្ងៃបុណ្យព្រះយេស៊ូប្រសូត ព្រះជាម្ចាស់នឹងយាងមកគង់ជាមួយយើង។ ក្នុងរយៈពេល ៤សប្តាហ៍នេះ ព្រះសហគមន៍ដាស់តឿនឱ្យគ្រីស្តបរិស័ទទាំងអស់ត្រៀមខ្លួនទទួលព្រះគ្រីស្តដែលកំពុងយាងមកសព្វថ្ងៃ។ ដូច្នេះ យើងត្រូវតែរៀបចំចិត្តគំនិត ព្រមទាំងប្រុងស្មារតីឱ្យបានល្អប្រសើរដើម្បីបង្កើតនូវសន្តិភាពឱ្យមានក្នុងដួងចិត្តគ្រប់ៗរូប និងមានអំណរសប្បាយទទួលព្រះយេស៊ូគ្រីស្ត ដែលនឹងយាងមកឱ្យបានសមរម្យជាទីបំផុត។





# ផ្កាយពន្លឺបំភ្លឺរាត្រីណូអែល

ប្រិយមិត្តត្រូវមាន : ក្រដាសកាតុងក្រាស់មួយ ខ្សែលួសទន់ ថ្នាំលាប ឬក្រលរពណ៌ កំប៉ាដែកគោល និងទៀន។



នៅលើក្រដាសកាតុង សូមប្រើប្រាស់កំប៉ាគូសរូបផ្កាយមួយ រួចកាត់វាចេញដោយប្រើកន្ត្រៃ កាំបិត និងបន្ទាត់។ ប្រយ័ត្នផង កុំឱ្យមុតដៃ!



យកខ្សែលួសមកបត់បង្កើតបានជាទម្រង់ផ្កាយរួចយកវាផ្តក់ភ្ជាប់នឹងផ្កាយក្រដាសកាតុងដោយដាក់កំពូលនីមួយៗត្រួតគ្នា។

ភ្ជាប់ផ្កាយខ្សែលួសទៅនឹងក្រដាសកាតុងដោយប្រើកំណាត់ខ្សែលួសតូចៗ ពាក់នឹងរន្ធ ដែលចោះនៅលើក្រដាសកាតុង។
ចុងកន្ទុយផ្កាយខ្សែលួសត្រូវមូលជារង្វេលដើម្បីដាក់ទៀនឱ្យត្រង់ក្នុងនោះ។




មិនត្រូវអុជទៀន ដោយគ្មានមនុស្សចាស់នៅក្បែរ ឬទុកចោលនោះឡើយ!

# លិខិតរបស់លោកអគ្គរាជទូតសម្តេចប៉ាបជូន"អ្នកនាំសារ" និងប្រិយមិត្ត

ខ្ញុំសូមផ្ញើនូវសារដ៏ពិសេសមួយជូនអ្នកអានព្រឹត្តិបត្រ អ្នកនាំសារ ទាំងអស់។ ជាកិច្ចចាប់ផ្ដើម ខ្ញុំសូមអបអរសាទរចំពោះក្រុមអ្នកនិពន្ធ និងសហការីទាំងអស់របស់ អ្នកនាំសារ។ អ្នកនាំសារ មានសេចក្ដីអំណរ និងពេញចិត្តក្នុងការពាំនាំនូវព័ត៌មាន ដើម្បីផ្សព្វផ្សាយជាសាធារណៈ ដូចជាព្រឹត្តិការណ៍ក្នុងប្រទេសកម្ពុជា ដែលក្នុងនោះ មិនគ្រាន់តែមាន ដំណឹងរបស់ព្រះសហគមន៍ក្នុងប្រទេសប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់ព្រះសហគមន៍ទូទាំងសកលលោកផងដែរ។ ជាពិសេស ខ្ញុំសូមថ្លែងអំណរគុណ អ្នកនាំសារ សម្រាប់លេខពិសេស នៅក្នុងឱកាសពិធីបុណ្យចូលរួមកាន់ទុក្ខសពរបស់សម្ដេចប៉ាប យ៉ូហាន ប៉ូល ទី២ ដែលជាអ្នកបម្រើព្រះជាម្ចាស់ និងសម្រាប់ពិធីពិសេសផ្សេងៗទៀត រួមទាំងការបោះឆ្នោតជ្រើសតាំងសម្ដេចប៉ាបបេណេឌីក ទី១៦ ផងដែរ។

ខ្ញុំដឹងថា អ្នកនាំសារ ក៏បានបង្ហាញព័ត៌មានពិសេស អំពីការជួបជុំគ្នារបស់យុវជនពិភពលោកនៅទីក្រុងកូឡូញ ប្រទេសអាឡឺម៉ង់ ជាមួយនិងប្រតិភូដែលជាយុវជនមកពីប្រទេសកម្ពុជា។ "ពិធីអរព្រះគុណព្រះជាម្ចាស់ គឺជាចំណុចកណ្ដាលមួយនៃជីវិតរស់នៅរបស់យើង"។ នេះគឺជាការអះអាងរបស់សម្ដេចប៉ាបបេណេឌីក ទី១៦ នៅពេលថ្លែងទៅកាន់យុវជនទាំងអស់ក្នុងទីក្រុងកូឡូញ។

ថ្ងៃនេះ ខ្ញុំបញ្ជាក់នូវអត្ថន័យដូចគ្នានេះ ទៅកាន់បងប្អូនរាល់គ្នា ដើម្បីលើកទឹកចិត្តក្នុងការស្វែងរកនូវកម្លាំងពីព្រះជាម្ចាស់ដើម្បីដឹកនាំជីវិតប្រចាំថ្ងៃរបស់បងប្អូន និងពីព្រះវិញ្ញាណដ៏វិសុទ្ធ តាមរយៈពិធីអរព្រះគុណព្រះជាម្ចាស់ និងជីវិតរបស់ព្រះសហគមន៍។ តាំងនាមខ្ញុំជាតំណាងរបស់សម្ដេចប៉ាបប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមជូនពរឱ្យអ្នកអាន អ្នកនាំសារ កាន់តែមានចំនួនកើនឡើងនៅគ្រប់ភូមិភាគដោយទទួលបានពីព្រះពរ។ នៅពេលដែលខ្ញុំមានកិត្តិយសបានចូលគាល់សម្ដេចប៉ាបបេណេឌីក ទី១៦ កាលពីថ្ងៃទី៦ ខែកក្កដា ខ្ញុំបានទូលដល់ព្រះអង្គអំពីការស្វាគមន៍ និងភក្ដីភាព នៃព្រះសហគមន៍នៅទីនេះ និងស្នើឱ្យមានការប្រទានពរដល់បងប្អូនទាំងអស់គ្នា។ បុណ្យព្រះយេស៊ូប្រសូតជិតឈានចូលមកដល់ហើយ ខ្ញុំសូមអធិដ្ឋានសម្រាប់បងប្អូនទាំងអស់គ្នា ឱ្យបំពេញការងារប្រកបដោយព្រះពរដ៏បរិបូរអំពីព្រះជាម្ចាស់ជារៀងរហូត។ សូមព្រះជាម្ចាស់ ប្រទានពរដល់បងប្អូន [illegible]

សាលវ៉ាទ័រ ពេណ្ណាស៊ីអូ

សម្លៀកបំពាក់ខ្មៅៈ លោកសាលវ៉ាទ័រ ពេណ្ណាស៊ីអូ រាជប្រតិភូសម្ដេចប៉ាបនៅប្រទេសឡាវ និងជាអគ្គរាជទូតរបស់សម្ដេចប៉ាបនៅប្រទេសកម្ពុជា ចូលជួបធ្វើសវនាការសម្ដេចប៉ាបបេណេឌីក ទី១៦ នៅទីក្រុងរ៉ូម ប្រទេសអ៊ីតាលី កាលពីថ្ងៃទី៦ កក្កដា ឆ្នាំ២០០៥



Photo: DR

## ព្រឹត្តិការណ៍នឹងមាន!

- ថ្ងៃ២ ធ្នូៈ ដំណើរទស្សនកិច្ច និងចុះសួរសុខទុក្ខរបស់អគ្គរាជទូតសម្ដេចប៉ាបទៅកាន់ព្រះសហគមន៍កំពង់ចាម។
- ថ្ងៃ៣ ធ្នូៈ ការទទួលជំហានទី១ របស់អ្នករៀនអប់រំជំនឿ នៅព្រះសហគមន៍ កអណ្ដើកនៃភូមិភាគកំពង់ចាម ដឹកនាំដោយលោកអគ្គរាជទូតសម្ដេចប៉ាប។
- ថ្ងៃ៤ ធ្នូៈ ការទទួលស្វាគមន៍លោកអគ្គរាជទូតរបស់សម្ដេចប៉ាបនៅព្រះសហគមន៍ផ្សារតូច នៅក្នុងភូមិភាគភ្នំពេញ។
- ថ្ងៃ៤-៥ ធ្នូៈ គណៈប្រតិភូវ៉ាំងសង់ដឺប៉ូលនៅអាស៊ីមកធ្វើទស្សនកិច្ចនៅកំពង់ចាម។
- ថ្ងៃ១០ ធ្នូៈ មានរៀបចំប្រជុំអន្តរនិកាយនៅព្រះសហគមន៍កំពង់ចាម។
- ថ្ងៃ១១ ធ្នូៈ ពិធីសម្ពោធសាលាមត្តេយ្យ និងបឋមសិក្សានៅកោះរកា កំពង់ចាម។
- ថ្ងៃ១៨ ធ្នូៈ ពិធីជប់លៀងរំលឹកបុណ្យណូអែលសម្រាប់កុមាររៀនអប់រំជំនឿ និងមនុស្សធំ នៅព្រះសហគមន៍ផ្សារតូច។
- ថ្ងៃ២៥ ធ្នូៈ មានកូនក្មេង ១០នាក់ នឹងត្រូវបានគេរៀបចំពិធីទទួលព្រះកាយឱ្យ ជាលើកដំបូងនៅព្រះសហគមន៍កំពង់សោម។
- ថ្ងៃ២៥ ធ្នូៈ ក្នុងឱកាសបុណ្យអបអរព្រះយេស៊ូយាងមក នៅកំពង់ចាម មានធ្វើទិវាប្រកាសជំនឿ មានដាក់ស្តង់លក់នំចំណី និងការលេងល្បែងកំសាន្តផងដែរ។

កម្មវិធីវិទ្យុៈ យុវវ័យសម័យទំនើប!
មានចាក់ផ្សាយនៅវិទ្យុគ្រួសារ FM 99.5 MHz វេលាម៉ោង ១៣:៣០នាទី និងផ្សាយឡើងវិញនៅម៉ោង ២០:៣០នាទី រៀងរាល់ថ្ងៃសៅរ៍។ ទូរស័ព្ទ ០១៦ ៣២៦៧៣៧ ។
សូមកុំភ្លេច!

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត រាជធានី ភ្នំពេញ
Tel/Fax: (855) 23 224 120 E-mail: csc@catholiccambodia.org & Website: www.catholiccambodia.org
អភិបាលគ្រប់គ្រងៈ លោកអភិបាល អេមីល ដេតម្បូ អគ្គនាយកៈ លោកបូជាចារ្យ ហៃរណាន់ ពីនីឡា